ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៦០៦ ព.ណ ន.អវឯទ

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយប្រចាំសប្តាហ៍ចាប់ពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦

- យោងប្រកាសអន្តរក្រសួងលេខ០០៨៣ ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់និងអន្តរជាតិ

រាជរដ្ឋាភិបាលបាន **១.** បន្តបញ្ចុះចំនួន ៦,៥សេនដុល្លារ/លីត្រ ក្នុងគោលបំណងជួយសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋ **២.** **បន្តបញ្ចុះ ១សេនដុល្លារ/លីត្របន្ថែមទៀត** ដោយសារថ្លៃប្រេងសាំងអន្តរជាតិឡើងលើសពី ៩០ដុល្លារ/បារ៉ែល និងប្រេងម៉ាស៊ូតអន្តរជាតិឡើងលើស ១០០ដុល្លារ/បារ៉ែល **៣.** **ពន្ធគយ ០ (សូន្យ) ដុល្លារ** និង **៤.** ផ្អែកតាមសភាពការណ៍ និងថ្លៃប្រេងឥន្ធនៈបន្តកើនឡើងនៅទីផ្សារអន្តរជាតិ ក៏ដូចជាថ្លៃដឹកជញ្ជូននិងថ្លៃធានារ៉ាប់រងមានការកើនឡើងខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសម្រេច **បញ្ចុះអាករបន្ថែមលើប្រេងសាំង និងប្រេងម៉ាស៊ូតមក ០ (សូន្យ) ដុល្លារ, បញ្ចុះអាករពិសេសលើប្រេងសាំងពី ៣០% មក ១៥% នឹងប្រេងម៉ាស៊ូត ពី ៤% មក ០%** **និង** **បញ្ចុះអាករលើតម្លៃបន្ថែមលើប្រេងសាំងពី ១០% មក ៤% និងប្រេងម៉ាស៊ូត ពី ១០% មក ០% ដោយរាជរដ្ឋាភិបាលទទួលបន្ទុកជំនួសសរុបចំនួន ៦% សម្រាប់ប្រេងសាំង និង ១០% សម្រាប់ប្រេងម៉ាស៊ូត**។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈត្រូវអនុវត្ត**ជារៀងរាល់សប្តាហ៍ចាប់ពីវេលាម៉ោង ១ រសៀលថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦** គឺត្រូវលក់ **៤ ៣០០រៀល/លីត្រ** សម្រាប់ប្រេងសាំងធម្មតា ( Gasoline 92 ) និង **៤ ៩៥០រៀល/លីត្រ** សម្រាប់ប្រេងម៉ាស៊ូត ( Gasoil 10ppm )។

### តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ Gasoline 92 | ប្រេងម៉ាស៊ូត/លីត្រ Gasoil 10ppm |
|---|---|---|---|
| ១ | ថ្លៃប្រេងអន្តរជាតិជាមធ្យម (Average MOPS) | ០,៦៧៧៦ ដុល្លារ | ០,៩៣៤៣ ដុល្លារ |
| ២ | **ពន្ធ៖** | ០,០៧៨៥ ដុល្លារ | ០,០០០០ ដុល្លារ |
| | ពន្ធគយ | ០,០០០០ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០០០០ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករពិសេស (ប្រេងសាំងបញ្ចុះពី ៣០% មក ១៥% និងប្រេងម៉ាស៊ូតបញ្ចុះពី ៤% មក ០%) | ០,០៧៨៥ ដុល្លារ | ០,០០០០ ដុល្លារ |
| ៣ | បុព្វលាភ (Premium) | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | **អាករលើតម្លៃបន្ថែម** (ប្រេងសាំងបញ្ចុះពី ១០% មក ៤% និងប្រេងម៉ាស៊ូតបញ្ចុះពី ១០% មក ០%) | ០,០៣៨២ ដុល្លារ | ០,០០០០ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ ( គិតជាដុល្លារ ) | ០,៩៩៤៣ ដុល្លារ | ១,១៦៤៣ ដុល្លារ |
| ៦ | ថ្លៃធានានិរន្តរភាពនៃការផ្គត់ផ្គង់ (ដោយគិតបញ្ចូលទាំងថ្លៃដឹកជញ្ជូន និងសេវាធានារ៉ាប់រងដែលក្រុមហ៊ុនត្រូវទទួលបន្ទុក) | ០,០៧១៥ ដុល្លារ | ០,០៦៥០ ដុល្លារ |
| ៧ | ក្រុមហ៊ុនប្រេងឥន្ធនៈបញ្ចុះតម្លៃ | ០,០១ ដុល្លារ | ០,០១ ដុល្លារ |
| ៨ | ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ ( គិតជាដុល្លារ ) | ១,០៦ ដុល្លារ | ១,២២ ដុល្លារ |
| ៩ | ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ ( គិតជារៀល ) | ៤ ៣០០ រៀល | ៤ ៩៥០ រៀល |

**សម្គាល់៖** - ថ្លៃប្រេងឥន្ធនៈមុនការបញ្ចុះអាករបន្ថែម, អាករពិសេស និងអាករលើតម្លៃបន្ថែម៖ **ប្រេងសាំង ៤ ៦៥០រៀល/លីត្រ និងប្រេងម៉ាស៊ូត ៥ ៤០០រៀល/លីត្រ**។
- អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦ ដែលស្មើនឹង ៤ ០៤០រៀល/ដុល្លារអាម៉េរិក។
- ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាដែលបានគណនា និងបង្ហាញខាងលើ គឺផ្អែកលើតម្លៃប្រេងឥន្ធនៈដែលបានប្រែប្រួលនៅលើទីផ្សារអន្តរជាតិ ស្របតាមប្រកាសរួមដូចបានយោងខាងដើម។ បណ្តាស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា អាចលក់ប្រេងក្នុងតម្លៃណាមួយ ដែលទាបជាងថ្លៃដែលបានគណនាខាងលើ តាមការប្រកួតប្រជែងជាក់ស្តែងនៃទីផ្សារនៅកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបថាថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ នឹងត្រូវដាក់ចេញជារៀងរាល់**ថ្ងៃអង្គារ វេលាម៉ោង ១ រសៀល** និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិឱ្យបានគត់មត់តាមសេចក្តីជូនដំណឹងនេះ។

១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ...២៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh